អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ R4C

**សកម្មភាព** ៖ ល្បែងស្វែងរកប្រភេទសំរាមក្នុងធុងតែមួយ

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖

ការហ្វឹកហាត់បង្កើតកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក៖

**វិទ្យាសាស្ត្រ** ៖ បំណិនអនាម័យ៖ ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារនិងសង្គម៖

**សិក្សាសង្គម** ៖ បំណិនក្នុងសង្គម៖ ការយល់ដឹងអំពីបរិស្ថានធម្មជាតិនិងវិធីការពារ៖

**បុរេគណិត** ៖ បរិមាណនិងចំនួន៖ ស្គាល់នឹងយល់លេខតាងនិងការគណនាលេខសាមញ្ញ៖

ទំហំនិងពណ៌៖ ចំណាត់ថ្នាក់ក្រុមនិងលំដាប់លំដោយ៖

**ភាសាខ្មែរ** ៖ ការប្រើពាក្យតាមវេយ្យាករណ៍៖ ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ៖

**គោលបំណង**

**ចិត្តចលភាព** ៖ បំណិនសម្បទា៖

កំណត់ចំណុចគោលដៅនៃចលនាដៃដោយការទប់លំនឹងនិងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយឬលែងល្បែងបានរឹងមាំល្អ។

**វិទ្យាសាស្ត្រ** ៖ បំណិនសម្បទា៖ ចោលសំរាមក្នុងធុងសំរាម

**សិក្សាសង្គម** ៖ បំណិនសម្បទា៖ ជួយសម្អាតបរិស្ថាន ដូចជាការបោសសំរាម និងមិនបន្ទោរបង់ផ្តេសផ្តាសជាដើម។

**បុរេគណិត** ៖ បំណិនសម្បទា៖ រាប់ចំនួនលេខ និងយល់ន័យពី១ដល់៣០ឬលើសពីនេះ។

បំណិនសម្បទា៖ រៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ ប្រាប់ពីពាក្យ ឃ្លា ឬល្បះ ឱ្យបានត្រឹមត្រូវទៅតាមស្ថានភាព មនុស្សធំដែលមានចំនួនពី៥ទៅ៦ព្យាង្គឬលើសពីនេះ។

**កម្រិតសិក្សា** ៖ មធ្យមនិងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កាតមានពីរប្រភេទ (ពណ៌ / សខ្មៅ)។ កាតធុងសំរាមមាន៥ប្រភេទ

កាតធុងសំរាម៥ប្រភេទ៥ពណ៌ (ប្រភេទសំរាមមាន៖១. ពណ៌ស្វាយសំណល់ក្រដាស ២. ពណ៌ខៀវសំណល់កំប៉ុង

៣.ពណ៌បៃតងសំណល់ផ្ទះបាយ ៤. ពណ៌លឿងសំណល់ប្លាស្ទីក និង ៥. ពណ៌ក្រហមសំណល់គ្រោះថ្នាក់ )។ កាតរូបភាពសំរាមតូចៗដែលមានរូបភាពសំរាមតាមធុងសំរាមនីមួយៗ ដែលកាត់វា និងអ៊ុតវាឱ្យបានស្អាតផងដែរ។ បញ្ជាក់៖ កាតធំមានទំហំ A5

**ការរៀបចំ** ៖ ត្រូវត្រៀម សម្ភារសម្រាប់លេងល្បែងនេះឱ្យបានគ្រប់គ្រាន់ ដោយកុមារត្រូវរៀបជាក្រុមៗ និងកាតត្រូវគ្រប់គ្នាផងដែរ។

**សេចក្តីណែនាំ** ៖

1. ប្រាប់កុមារៗពីប្រភេទសំរាមនីមួយៗដែលមានក្នុងការលេងល្បែងនេះ ដោយអាចសួរកុមារថាតើអ្វីទៅដែលហៅថាសំរាម? តើសំរាមមានប៉ុន្មានប្រភេទ?
2. សួរក្មេងៗថាមានស្គាល់សំរាមទាំងអស់នោះអត់? សួរកុមារថាមានដឹងពីរបៀបចោលសំរាមដែរឬទេ? និងប្រាប់កុមារពីការចោលសំរាមឱ្យបានត្រឹមត្រូវឱ្យច្បាស់មុននឹងលេងល្បែងសកម្មភាពមួយនេះផងដែរ។
3. ប្រាប់កុមារពីរបៀបលេងល្បែងនេះសិន៖
    - ចែកកុមារជាក្រុមៗដែលមានសមាជិកចំនួន៥នាក់តាមចំនួនធុងសំរាមដែលមាន។
    - ចែកសម្ភារដែលមានស្រាប់ទៅតាមក្រុមនីមួយៗដែលបានរាប់ចំរួចរាល់ សម្ភារមាន៖ ក្រដាសកាតសំណល់សំរាម ទាំង៥ និងកាតរូបភាពសំណស់សំរាមដែលកាត់រួច និងអ៊ុតបានស្អាតរួចនោះ។
    - ក្នុងក្រុមនីមួយៗចាប់ផ្តើមលេង ដោយត្រូវរកសមាជិកម្នាក់ដែលអាចចាប់ផ្តើមមុនដោយប៉ាវ ឬវិធិសាស្រ្តផ្សេងទៀតក៏បានដែរ។
    - កុមារទាំងអស់ត្រូវអង្គុយជារង្វង់
    - ក្រុមនីមួយៗត្រូវចែកក្រដាសធុងសំរាមដោយសមាជិកម្នាក់មួយៗ ហើយបន្ទាប់ត្រូវដាក់នៅចំពីមុខខ្លួន រៀងៗខ្លួន
    - និងកាត់រូបភាពតូចៗទាំងអស់ត្រូវផ្កាប់និងច្រប់ឱ្យសព្វនៅកណ្តាលទាំងអស់
    - កុមារដែលត្រូវបានចាប់ផ្តើមមុន ត្រូវបើកកាត់មួយសន្លឹក បន្ទាប់មកមើលថាត្រូវជាប្រភេទសំណល់ដែលត្រូវនឹងធុងសំរាមរបស់ខ្លួនមានដែរឬទេ? ប្រសិនបើដូចត្រូវរក្សាទុកនៅមុខរបស់ខ្លួន ប៉ុន្តែប្រសិនបើមិនមែនជាប្រភេទសំណល់ដែលដូចនឹងធុងសំរាមទេនោះ ត្រូវផ្កាប់កាតរូបភាពហ្នឹងវិញ នៅកន្លែងដដែល។

- ក្នុង១នាក់ត្រូវស្វែងរកកាតរូបភាពសំណល់ឱ្យបាន៦ (ដែលមានកាតរូបភាពសំណល់៦ប្រភេទដែលដូចនឹងប្រភេទធុងសំរាមរបស់ពួកគេ)។ ដូច្នេះប្រសិនបើកុមារដែលអាចបើករកកាតរូពភាពបានគ្រប់៦មុន នឹងក្លាយជាអ្នកឈ្នះទី១ និងទី២ រហូតដល់ទី៥ផងដែរ។
- កុមារអាចលេងប្រកាន់ខាងស្តាំទៅបាន កុមារបន្ទាប់ត្រូវតែកុមារខាងស្តាំដៃតែប៉ុណ្ណោះ។

4. លេងបែបនេះរហូតទាល់តែអស់កាត់រូបភាពតូចៗក្នុងផ្នែកខាងក្នុងរង្វង់គឺជាការស្រេចតែម្តង។